## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ ០០៤ សសរ

## សេចក្តីសម្រេច
### ស្តីពី
### ការបង្កើតគណៈកម្មការធ្វើកោសល្យវិច័យអគាររបស់ឈ្មោះ ឯក សារុន និងប្រពន្ធឈ្មោះ ឈីវ សុធី ដែលបានបាក់រលំនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ ១.** បង្កើតគណៈកម្មការធ្វើកោសល្យវិច័យអគាររបស់ឈ្មោះ ឯក សារុន និងប្រពន្ធឈ្មោះ ឈីវ សុធី ដែលបានបាក់រលំនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **នេព ធន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ចិន សម្បត្តិថាវរ័ត្ន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ឆាន់ សុវុទ្ធផល** | អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់ | សមាជិក |
| ៤. លោក **និត ខេមរា** | ប្រធាននាយកដ្ឋានសំណង់នៃអគ្គនាយកដ្ឋានសំណង់ | សមាជិក |
| ៥. លោក **ជីវ ស៊ីវឆេង** | ប្រធាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់នៃអគ្គនាយកដ្ឋានសំណង់ | សមាជិក |


អាសយដ្ឋាន: ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីម៉ែល mlmupc.cabinet@gmail.com

| | | |
|---|---|---|
| ៦. លោកឈុន សុខសាន្ត | ប្រធានមន្ទីរពិសោធន៍ | សមាជិក |
| ៧. លោក នេត ខ៊ែតពិសាល | អនុប្រធាននាយកដ្ឋានភូមិសាស្ត្រ<br>នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | សមាជិក |
| ៨. លោក ឃួន សេរី | អនុប្រធាននាយកដ្ឋានអភិវឌ្ឍសេដ្ឋកិច្ច<br>កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ<br>នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៩. លោក ទៅ សុខា | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់<br>និងសុរិយោដីខេត្តកែប | សមាជិក |
| ១០. លោក ទិត្យ ជុល | ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម<br>សំណង់និងភូមិបាលក្រុងកែប | សមាជិក |
| ១១. លោក ថន ទិត្យា | មន្ត្រីនាយកដ្ឋានសិក្សាគម្រោងប្លង់<br>នៃអគ្គនាយកដ្ឋានសំណង់ | សមាជិក |

**ប្រការ ២.** គណៈកម្មការមានភារកិច្ចដូចខាងក្រោម÷

- ធ្វើកោលស្សវិច័យអគាររបស់ឈ្មោះ ឯក សារុន និងប្រពន្ធឈ្មោះ ឈីវ សុធី ដែលបានបាក់រលំ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប
- ត្រួតពិនិត្យលក្ខណសម្បត្តិរបស់អ្នកសាងសង់
- ធ្វើរបាយការណ៍លទ្ធផលជូនក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

**ប្រការ ៣.** គណៈកម្មការអាចប្រើប្រាស់មន្ត្រីក្រោមឱវាទ ដើម្បីបំពេញការងារតាមការចាំបាច់។

**ប្រការ ៤.** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៥.** នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសាមីខ្លួនដូចក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល:**
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលខេត្តកែប
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ